# ឧបករណ៍ឱ្យសញ្ញាពេលមានផ្សែង

តាមច្បាប់ គ្រប់លំនៅដ្ឋានទាំងអស់ក្នុងរដ្ឋវិចថូរៀ ត្រូវតែបានដំឡើងឧបករណ៍ឱ្យសញ្ញាពេលមានផ្សែងយ៉ាងហោចណាស់មួយ នៅតាមជាន់លំនៅដ្ឋាននីមួយៗ។

អាជ្ញាធរ FRV និង CFA ណែនាំឱ្យប្រើឧបករណ៍ឱ្យសញ្ញាពេលមានផ្សែងដែលប្រើថ្មពិលលីធៀម (lithium) មានប្រសិទ្ធិភាព១០ឆ្នាំ ហើយនៅក្នុងកូនប្រអប់ដែលគេពុំអាចធ្វើឱ្យខូចខាតបាន។

- ឧបករណ៍ឱ្យសញ្ញាពេលមានផ្សែងទាំងអស់នៅក្នុងផ្ទះរបស់អ្នកគួរតែបានតភ្ជាប់គ្នា។
- ទាំងនេះអាចជាឧបករណ៍ដែលមិនតភ្ជាប់ទៅភ្លើងអគ្គិសនី (មិនតភ្ជាប់ទៅភ្លើងអគ្គិសនីប្រើកម្លាំង ២៤0v) ឬដែលតភ្ជាប់ទៅភ្លើងអគ្គីសនី (តភ្ជាប់ទៅភ្លើងអគ្គិសនីប្រើកម្លាំង ២៤0v)។







## ប្រចាំខែ

- ចុចប៊ូតុងធ្វើតេស្ត ដើម្បីឱ្យប្រាកដថាឧបករណ៍កំពុងដំណើរការ
- សង្កត់រហូតទាល់តែឧបករណ៍បញ្ចេញសម្លេងរោទិ៍បីដង

## ប្រចាំឆ្នាំ

- ជូតធូលីដី ឬជូតសម្អាតជុំវិញគម្រប ឧបករណ៍ឱ្យសញ្ញាពេលមានផ្សែងដោយថ្នមៗ
- ប្រសិនបើអ្នកមានឧបករណ៍ឱ្យសញ្ញាពេលមានផ្សែងប្រើថ្មពិលកម្លាំង៩វ៉ុល ចូរប្ដូរថ្មពិលថ្មីជារៀងរាល់ឆ្នាំ

## ប្ដូរថ្មីជារៀងរាល់១០ឆ្នាំម្ដង

- ឧបករណ៍ឱ្យសញ្ញាពេលមានផ្សែងទាំងអស់ (តភ្ជាប់ទៅភ្លើងអគ្គីសនី និងមិនតភ្ជាប់ទៅភ្លើងអគ្គិសនី) ចាំបាច់ត្រូវតែដូរថ្មី

FIRE RESCUE VICTORIA

CFA

# តើខ្ញុំត្រូវដំឡើងឧបករណ៍ឱ្យសញ្ញាពេលមានផ្សែងរបស់ខ្ញុំនៅកន្លែងណា ?

- គួរដំឡើងឧបករណ៍ឱ្យសញ្ញាពេលមានផ្សែងនៅលើពិដាន យ៉ាងហោចណាស់៣០សង្ទីម៉ែត្រពីជញ្ជាំង។
- ត្រូវដំឡើងឧបករណ៍ឱ្យសញ្ញាពេលមានផ្សែងនៅចន្លោះកន្លែងគេងនីមួយ និងនៅតាមកន្លែងសេសសល់ទាំងប៉ុន្មានក្នុងផ្ទះ។
- សេវាកម្មពន្លត់អគ្គិភ័យអូស្ត្រាលី សូមណែនាំឱ្យដំឡើងឧបករណ៍ឱ្យសញ្ញាពេលមានផ្សែងនៅគ្រប់កន្លែងរស់នៅ ផ្លូវដើរក្នុងផ្ទះ បន្ទប់គេង ឬបន្ទប់ណាមួយដែលមាននរណាម្នាក់គេង។
- ឧបករណ៍ឱ្យសញ្ញាពេលមានផ្សែងត្រូវបំពេញតាមស្តង់ដាអូស្ត្រាលី AS៣៧៨៦។

Certified Product
Australian Standard

■ ត្រូវមានទីតាំងនៅចន្លោះកន្លែងគេង និងនៅតាមកន្លែងសេសសល់ទាំងប៉ុន្មានក្នុងផ្ទះ

● កន្លែងបន្ថែមទៀតដែលអ្នកអាចដំឡើងឧបករណ៍ឱ្យសញ្ញាពេលមានផ្សែង ដើម្បីផ្តល់កិច្ចការពារបន្ថែម




មានតែឧបករណ៍ឱ្យសញ្ញាពេលមានផ្សែងដែលដំណើរការប៉ុណ្ណោះ ជួយសង្គ្រោះជីវិត។
សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីឧបករណ៍ឱ្យសញ្ញាពេលមានផ្សែង សូមស្កេននៅទីនេះ។
សម្រាប់ព័ត៌មានបន្ថែមអំពីសុវត្ថិភាពអគ្គិភ័យសូមចូលមើល frv.vic.gov.au/cfa.vic.gov.au